ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០៣៨/២៥ ក.ប/ស.ជ.ណ.ម.ព

# សេចក្តីជូនដំណឹង
## ស្តីពី
## ការស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេសសម្រាប់ឆ្នាំ២០២៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងជនបរទេសប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថាអនុលោមតាមច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា និងប្រកាសលេខ ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីបណ្ណការងារ និងសៀវភៅការងារជនបរទេស ក្រសួងសូមជម្រាបជូនដូចខាងក្រោម៖

១. ចំពោះជនបរទេស ដែលធ្លាប់មានបណ្ណការងារ និងសៀវភៅការងារ ត្រូវស្នើសុំពន្យារសុពលភាពបណ្ណការងារ និងសៀវភៅការងារជនបរទេស ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦។

២. ចំពោះជនបរទេស ដែលទើបចូលមកធ្វើការងារ ឬប្រកបមុខរបរណាមួយនៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឱ្យបានមុនរយៈពេល ៩០ថ្ងៃ បន្ទាប់ពីចូលមកដល់ព្រះរាជាណាចក្រកម្ពុជា។

ការស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស ត្រូវធ្វើឱ្យបានមុនកាលបរិច្ឆេទខាងលើនេះជាកំហិត តាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh។ ចំពោះការខកខានមិនបានអនុវត្តតាមកាលកំណត់ខាងលើ ក្រសួងនឹងចាត់វិធានការផាកពិន័យស្របតាមជំពូកទី១៦ នៃច្បាប់ស្តីពីការងារ និងប្រកាសអន្តរក្រសួងលេខ ៤៩៨ សហវ.ប្រក.អទច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងជនបរទេសទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

ថ្ងៃ ចន្ទ ៣កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- គ្រប់សមាគមនិយោជក
- ឯកសារ កាលប្បវត្តិ